# ការសំភាសន៍របស់អ៊ុំប្រុស គីវ ប៉ុនណូ

**កៈ អ្នកធ្វើការសម្ភាសឈ្មោះ វេសស្លី ក្រឹម ខៈ អ្នកត្រូវគេសម្ភាស គីវ ប៉ុនណូ**

កៈ អូខេ ថ្ងៃនេះជាថ្ងៃទី ២៨ ខែ ១ ឆ្នាំ ២០១៧។ ខ្ញុំបាទឈ្មោះ វេសស្លី ក្រឹម មកថ្ងៃនេះ ហើយធ្វើការសម្ភាសជាមួយនឹងអ៊ុំ...។

ខៈ ប៉ុនណូ។

កៈ អ៊ុំប៉ុនណូ ហើយអញ្ចឹងដំបូង អ៊ុំមានសាកលវិទ្យាល័យមួយនៅអាមេរិចដោយកំពុងធ្វើគម្រោង ឲ្យយល់ដឹងច្រើនថែមទៀតអំពីក្រុមគ្រួសារហើយប្រជាជនខ្មែរ ហើយយល់ដឹងអំពីបទពិសោធន៍ ក្នុងជីវិតរបស់ពួកគាត់។ ហើយអញ្ចឹងខ្ញុំមកមានគម្រោងអាចសួរសំណួរ ខ្លះៗទាក់ទងនឹងជីវិត និង បទពិសោធន៍ទាំងឡាយក្នុងជីវិតរបស់អ៊ុំប្រុស។ អញ្ចឹងនៅពេល ដែលខ្ញុំថតសម្លេងមួយនេះ ខ្ញុំសុំ ការអនុញ្ញាតពីអ៊ុំ ហើយបង្ហោះការសម្ភាសនេះទៅវេបសាយរបស់ប៊ីវាយយូបានទេ?

ខៈ បានអត់បញ្ហា... No problem!

កៈ បាទ! អញ្ចឹងយើងចាប់ផ្តើម... សុំស្គាល់ឈ្មោះពេញរបស់អ៊ុំ។

ខៈ ឈ្មោះខ្ញុំពេញ គីវ ប៉ុនណូ អាយុ ៦៥ ឆ្នាំ។ ខ្ញុំរស់នៅភូមិចម្ការសម្រោង២ សង្កាត់ចម្ការ សម្រោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

កៈ អូខេ! ហើយសួរថាកាលពីក្មេងឬក៏សព្វថ្ងៃមានឈ្មោះហៅក្រៅអេ៎?

ខៈ អត់មានឈ្មោះហៅក្រៅទេ មានឈ្មោះតែមួយហ្នឹង លុះស្លាប់ទៅវិញ។

កៈ ឈ្មោះតែមួយហ្នឹង អូ! ហើយតើអ៊ុំបានកើតនៅណា?

ខៈ ខ្ញុំកើតនៅស្រុកស្ទោង ខេត្តកំពង់ធំ។

កៈ ហើយឥឡូវសព្វថ្ងៃនេះ អ៊ុំមានអាយុប៉ុន្មាន?

ខ៖ ៦៥ឆ្នាំ ឆ្នាំថ្មី។

ក៖ ហើយអញ្ចឹងចាំឆ្នាំដែលអ៊ុំកើតទេ?

ខ៖ ខ្ញុំកើតថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៥២។

ក៖ ចុះឆ្នាំខ្មែរ? ឆ្នាំដូចជាសត្វអីគេ?

ខ៖ អូ! សត្វហ្នឹងសត្វពស់។

ក៖ ហើយអ៊ុំចាំកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍របស់អ៊ុំទេ?

ខ៖ អូ! អត់សួរពីរៀនទេ សួររៀបការម៉ងអេះ?

ក៖ យើងសួរពីរៀនដែរ ប៉ុន្តែ...

ខ៖ ខ្ញុំរៀបការនៅឆ្នាំ១៩៧៨... ដើម ៧៨ សម័យប៉ុលពត។

ក៖ បាទ! អញ្ចឹងសម័យប៉ុលពត វាត្រូវរៀបចំដោយនរណាឬក៏អ៊ុំប្រុស អ៊ុំស្រីជាអ្នករើស?

ខ៖ យើងអត់មានពួក... ពួកខ្មែរក្រហមអត់មានបង្ខំយើងទេ តំបន់ដែលខ្ញុំនៅហ្នឹង គេបើសិទ្ធិឲ្យយើងជ្រើសរើស ខ្ញុំជ្រើសរើសបានមួយហ្នឹង។

ក៖ បាទ! អញ្ចឹងអ៊ុំចាំដូចជាថ្ងៃដំបូងដែលបានអ៊ុំស្រីទេ?

ខ៖ ចាំ យើងសម័យហ្នឹងឆ្នាំ១៩៧៦ គាត់ធ្វើជាចុងភៅនៅការដ្ឋានពួកខ្មែរក្រហម ពួកសម្រាប់យុវជនយុវនារីដែលជាពលករលើកដី អញ្ចឹងខ្ញុំជាអ្នកបររទេះគោ។ យើងបររទេះគោដឹកស្បៀង ដឹកស្បៀងដឹកទៅកន្លែងគាត់ហ្នឹងដល់ខ្ញុំឃើញគាត់ខ្ញុំរៀងប្លែកភ្នែក។ ខ្ញុំដេញដោលសួរក្មួយប្រុសខ្ញុំ សួរថាម្នាក់ហ្នឹងនៅណា? គាត់នៅផ្ទះម្ដាយមីងខ្ញុំរំលងពីផ្ទះខ្ញុំពីរផ្ទះដល់ផ្ទះគាត់ ប៉ុន្តែសម័យនោះមានតែផ្ទះអត់មានមនុស្សនៅទេ ពីព្រោះយើងដើរនៅ... ដេកដោយព្រៃ ដោយវាល ស្រែ។ បាទ! ហើយខ្ញុំថានឹងក្មួយខ្ញុំថា ហែងចាំមើលអញដណ្ដឹងម្នាក់នេះឲ្យទាល់តែបានដូចថាគេ ថាឃើញភ្លាមស្រឡាញ់ភ្លែតអាំ។ បាទ! ខ្ញុំប្ដេជ្ញាៗ លើកទីមួយយើងចូលស្ដីដណ្ដឹងម្ដាយមីងឪពុក មាគាត់ សព្វថ្ងៃគាត់រស់នៅបែលសីក តែគាត់ចាស់អ៊ែ គាត់វង្វេងវង្វាន់អស់អ៊ែ។

បាទ! ហើយគាត់ ជាសាស្ត្រាចារ្យ ម្ដាយមីងគាត់ហ្នឹងបង្រៀននៅភ្នំពេញ។ យើងចូលទៅ ចូលទៅឆៅ តែខ្លួនឯងម៉ង។ គាត់សួរនាំយើងច្រើន។

កៈ បាទ!

ខៈ បាទ អញ្ចឹងទៅគាត់ហ្នឹងនាំពាក្យហ្នឹងទៅប្រាប់ប្រពន្ធខ្ញុំ។ ដល់ប្រពន្ធ ខ្ញុំនៅសម័យហ្នឹង គាត់អត់មានថានឹកឃើញចង់បានប្ដីអី អត់ទេ ហើយគាត់មនុស្សញុំាអត់ដែលឆ្អែត គាត់ស្គមស្គមមែនទែន។ គាត់ញុំាអត់មានអាហារញុំាគ្រាប់គ្រាន់ ទាំងខ្ញុំអីក៏អត់មានដែរ អត់មាន អាហារញុំាគ្រាប់គ្រាន់អ៉េ។ អញ្ចឹងគាត់អត់មានសប្បាយចិត្តនឹងចង់បានប្ដីអ៉េ គាត់ខឹងម៉ង។ ម្ដាយ មីងសួរអ៊ាំ គាត់ខឹង... ក្រោយមកយើងបានគ្នាហើយគាត់ប្រាប់ខ្ញុំ ប៉ុន្តែមិនដឹងចៃដន្យម៉េច ដល់យូរៗទៅ គាត់គិតឃើញថាអូ! គាត់បែក... អត់មានម្ដាយឪពុកអញ្ចឹង នៅជាមួយឪពុកមាម្ដាយមីងគេ សុទ្ធរស់រៀងខ្លួនម៉ង អ្នកណាមានអីញុំាហ្នឹង។ យើងអត់មានទៅរកអី បានញុំាក្រៅអ៉េ អញ្ចឹងគាត់ នឹកឃើញថា នឹកឪពុកនឹកម្ដាយនឹកបងប្អូននៅបាត់ដំបងនេះ។ គាត់អត់ មានអារម្មណ៍ចង់បានគ្រួសារតែថ្ងៃក្រោយមក គាត់បែរទៅជាព្រមនេះពរជ័យរបស់ខ្ញុំដែរ។ ដល់ព្រមទៅយើងសុំច្បាប់គេ គេអត់ឲ្យការពីព្រោះគាត់គេចាត់ទុកជា១៧ មេសា។ ១៧មេសារហ្នឹងក្រុមខ្មែរក្រហមរំដោះ ទីក្រុង ភ្នំពេញអ៊ាំ គាត់រៀននៅសាកលវិទ្យាល័យភ្នំពេញ ហើយខ្ញុំរៀននៅភ្នំពេញដែរ។ គេ ចាត់ទុកខ្ញុំជា អ្នកមូលដ្ឋាន ដោយសារឪពុកខ្ញុំអ្នកមូលដ្ឋាន ប៉ុន្តែប្រពន្ធខ្ញុំគេចាត់ទុកជាអ្នកថ្មី។ អ្នកថ្មីគេអត់ចូល ចិត្ត ដូចជាខ្មែរអត់ចូលចិត្តវៀតណាមអញ្ចឹង។ គេអត់ចូលចិត្ត... អ្នកថ្មីទាំងប៉ុន្មានហ្នឹង គម្រោងគេ ត្រូវសម្លាប់ចោលទាំងអស់ អញ្ចឹងក៏នឹកឃើញទៅបានគាត់ព្រម។ គាត់ព្រមដល់យើងសុំ ច្បាប់ការ គេអត់ឲ្យការ អញ្ចឹងថាអត់ទៀតអ៉ែចឹង។ មួយឆ្នាំមួយឆ្នាំហ្នឹងអត់ឲ្យការអ៉េ អញ្ចេះឪពុកខ្ញុំ ឪពុក គាត់ថាបើគេមិនឲ្យការទៅដណ្ដឹងអ្នកផ្សេងទៀតទៅ ហើយខ្ញុំអត់ចង់នៅស្រុកហ្នឹងទៀតអ៉េ ខ្វះអី កូនអ្នកស្រុកទៅណាក៏សឹងបានទាំងអស់ដោយសារយើងដូចថា ពូជអម្បូរគេស្គាល់ច្បាស់លាស់ អ៊ាំ។ ដល់អញ្ចឹងទៅខ្ញុំថាអត់ទេ បើអត់បានមួយហ្នឹងខ្ញុំអត់យកអ្នកណាអ៉េ។ ឆ្នាំក្រោយទៀត យើង ស្នើរសុំ គេទៀត ហើយខ្ញុំទៅកុហកគេម៉េច? ខ្ញុំកុហកគេ... កុហកប្រធានភូមិ ប្រធានភូមិធំអ៊ាំសម័យហ្នឹងអ៊ាំឲ្យយើងងាប់ៗឲ្យយើងរស់ៗ ហើយប្រធានភូមិហ្នឹងគាត់ធ្លាប់នៅមួយម្ដាយមីងខ្ញុំអត់ ចេះអក្សរអាលីង... សរសេរតែឈ្មោះឯងអត់ត្រូវផង។ ខ្ញុំថា «បង ម៉េចបានបងឯងអត់ឲ្យច្បាប់ខ្ញុំរៀប ការជាមួយប្រពន្ធខ្ញុំ? ហើយខ្ញុំស្រឡាញ់គ្នាតាំងពីនៅភ្នំពេញម៉េស។» តាមពិតយើងនិយាយកុហក គេអ៊ាំ... «បងឯងបំបែកបំបាក់ខ្ញុំម៉េស?» តែនិយាយតែប៉ុណ្ណឹង គាត់ថាចាំមើលបងគិតមើលសិន។ ដល់ហើយ គេហៅឲ្យធ្វើ ប្រវត្តិរូបរៀបការ។

កៈ ធ្វើភ្លាមៗ

ខៈ អឺរ! ហើយការហ្នឹងអត់មានអីធំដុំអ៎ សម័យប៉ុលពតហ្នឹង... គេអត់ឲ្យយើងធ្វើនៅផ្ទះ ផង គេមានកន្លែងជំនាន់ខ្ញុំ៧៨ គួរអ៎!គ្រាន់តែឡើងប្ដេជ្ញាចិត្តម្ដងមួយគូៗឡើងទៅដល់គោរពមេឃុំ មេភូមិអីហ្នឹង។ គេសួរដូចយើងឡើងថ្លែងសក្ខីភាពចឹង ហើយយើងប្ដេជ្ញាធ្វើតាមមាគ៌ារបស់អង្គការ ចេះតែប្ដេជ្ញាទៅ ឲ្យតែបាន ប្រពន្ធ គេឲ្យប្ដេជ្ញាៗទៅ ធ្វើមិនបានមិនដឹងធ្វើម៉េច។ ហើយសម័យហ្នឹង សម័យគេផ្ដោតខ្លាំងទៅលើ ការធ្វើកសិកម្ម ស្រែ... បង្កបង្កើនផល ស្រែមួយហិចតាឲ្យបានបីតោន ... បីពាន់គីឡូ។ យើងចេះតែប្ដេជ្ញាទៅ ប្ដេជ្ញាដើរតាមការដឹកនាំរបស់ខ្មែរក្រហមអាំ តាមការពិត គ្មាននរណាចូលចិត្តទៅរស់នៅក្នុងអា របបឆ្កួតចឹងទេ តែថាបើយើងទៅប្រឆាំងគេ គេអូសយើង ទៅវាយចោលនៅថ្ងៃអ៎។ ហើយតាំងពីហ្នឹងមក ការណឹងឆ្នាំហ្នឹងទឹកធំអាំ ទឹកធំលិចស្រែច្រូតស្រូវ ជិះទូកអាំ ហើយប្រពន្ធខ្ញុំអត់ចេះហែលទឹកអ៎។ អញ្ចឹងស្រែឆ្នាំហ្នឹងទឹកវាដូចជាទឹកជំនន់ ច្រើនអា ណាំ។ ស្រូវច្រូតបាន ដឹកទូកយកមកដាក់លើគោក ហើយស្រូវសម័យហ្នឹងកើតមែនដូចរាល់ថ្ងៃអ៎ កើតមែនទែន ហើយធ្វើការបែកគ្នារហូតអត់សូវបានជួបគ្នាទេ។ នៅពេលដែលគាត់យុវនារីអញ្ចឹង នៅពេលដែលគាត់មានគ្រួសារ គេឲ្យយើងចូលទៅក្រុមនារីដូចយុវជនយុវនារីយើងអាណាំ។ អាយុ ប៉ុណ្ណេះនៅនេះ ដល់នៅនេះ គេទៅសង្គមសង្គ្រោះ។ អញ្ចឹងគាត់ទៅច្រូតទៅ ខ្ញុំបរ សម័យហ្នឹងខ្ញុំ បររទេះគោ យើងដឹកជញ្ជូនរស់នឹងអាហ្នឹងហើយបើឲ្យយើងដកស្ទូងរែកដី... ងាប់បាត់អ៎។ យើង អត់មានអីញ៉ាំឆ្អែត អត់មានកម្លាំងអ៎ណាំ វេទនាអាំ វេទនាមែនទែន។ អាមួយនៅភូមិខ្ញុំសព្វថ្ងៃនៅ អាមេរិច អានោះដកសំណាបអូសគូទពីលើសំណាប សំណាបគេឲ្យដកស្រូវដូចយើង សាបអញ្ចឹង អាំ ដកយកទៅស្ទូងអាំ។ ខ្ញុំឃើញវាអាណោកអាធមអាំ ហើយអត់មានអ្នកណាជួយអ្នកណាបានទេ ទាល់តែស្រឡាញ់គ្នាណាស់ មានអីលួចចែកគ្នាញ៉ាំបើគ្រាន់តែស្គាល់គ្នាល្មមៗអត់អ៎ រករស់រៀង ខ្លួន។ ហើយសម័យហ្នឹង លួចតែគេចាប់បានដឹងតែគេយកវៃ ចោលម៉ង តែខ្ញុំកំពូលលួចៗ។

កៈ លួចអីខ្លះ?

ខៈ ទឹកត្នោត ទឹកត្នោតឡើងយប់។ ទឹកត្នោតខ្ញុំធ្វើស្ករអាំ... លួចឡើងផឹក... ឡើងដើមនេះពីរបីថ្ងៃ ឡើង ដើមនោះអត់មានឡើងដដែលៗអ៎ ឡើងដដែលតែគេចាប់បានដឹងតែគ្រោះថ្នាក់ តែប្រថុយ ចេះតែប្រថុយទៅសម័យនេះ។

កៈ ឡើងខ្លួនឯង ឬក៏មានក្រុមឡើង?

ខ៖ អត់ទេ ឡើងតែម្នាក់ឯង ម៉ោង ១២ យប់ម៉ោង ១... ឡើងក្បាលល្វាចទឹកត្នោតវាអត់ទាន់ចេញ ច្រើន ដល់ឡើងអាមួយនោះប៉ះគេធ្វើទឹកត្នោតជូរហាំស ... គេធ្វើទឹកត្នោតជូរផឹកស្រវឹងអាំ លែង ហែងលែងចុងចាក់ដាក់កំប៉ុងតយគេនៅលើហ្នឹង អានេះធ្វើទឹកត្នោតជូរ ឯងកេក ហាស់... រឿង ហ្នឹងខ្ញុំនិយាយបី ថ្ងៃអត់អស់ទេសម័យប៉ុលពត។

ក៖ បាទ! លួចអីទៀតអេំ?

ខ៖ លួចមាន់... លួចមាន់លួចផ្ទះមេខ្មែរក្រហមម៉ង ផ្ទះនៅជិតគ្នា ចន្លោះគ្នាប្រហែល ២០–៣០ ម៉ែត្រ ហើយរបងណែនចេស នៅតែលួចបានទៀត សាហាវអាំ ហាស... ជំនាញម៉ងរឿងលួច ប៉ុនបើលួច កុំទៅគ្នាពីរនាក់គ្រោះថ្នាក់អាំ តែចាប់បានអាមួយនោ គូសទាល់តែចេញ អញ្ចឹងទៅតែឯងៗហើយ អត់ចេះ ខ្លាចខ្មោចទេ ស្មាលណាក៏អត់ចេះខ្លាចខ្មោចដែរ។ ក្រពើអីក្នុងទឹក ទឹកស្ទឹងម៉ោងប៉ុន្មានក៏ខ្ញុំ ហ៊ានចុះដែរ។

ក៖ មានជួបក្រពើទេ?

ខ៖ អត់អេំ បើជួបវាសីទៅបាត់អ៉េំ ហាស់... ត្រីសម័យនោះនិយាយពីសម្បូរច្រើនណាស់ត្រីហើយ យើងពាក់មោងអាំ។ ដឹងម៉េចអេំ មោងកណ្តាចអាំ មោងហ្នឹងលួចគេទៀត និយាយពីថាដាក់ដល់ ទឹកជាប់ភ្លាម ដល់ជាប់ទៅមួយយប់ៗអត់សូវបានគេងអេំ យកអាត្រីហ្នឹងមករះពោះបង្កាត់ភ្លើង មកឆ្អើរ ឆ្អើរទុកបានយូរ ដល់ឆ្អើរតិចទៅ គេឲ្យខ្ញុំដឹកស្បៀង គេដកប្រពន្ធខ្ញុំហ្នឹងឲ្យទៅនៅ អាហ្នឹង និយាយមុនបានទេ មុនបានគ្នា ទៅដាំដំឡូងនៅស្រុកលើ ដល់ខ្ញុំទៅខ្ញុំឆ្អើរ ឆ្អើរអាត្រីហ្នឹងទៅយក ទៅផ្ញើរយកទៅផ្ញើរគាត់។ ខ្ញុំមានអីខ្ញុំឲ្យគាត់ ខ្ញុំស្រឡាញ់គាត់ ខ្ញុំឲ្យគេសីម៉េច ហើយឲ្យអត់ហ៊ាន យកទៅឲ្យខ្លួនឯងទៀត យកទៅឲ្យខ្លួនឯង គេឃើញគេថាខុសសីលធម៌ គេសម្លាប់យើង ច្បាប់ ហ្នឹងតឹងណាំ ឲ្យតែខុសសីលធម៌អត់ដែលរួចខ្លួនទេ ឲ្យតែស្រឡាញ់គ្នាមុនអាំ លួចស្រឡាញ់គ្នា... បើពួកវាពួកអាខ្មែរក្រហមខ្លះ វាឃើញយើងស្អាតអញ្ចឹង វាណាត់ទៅសម្ភាស ទៅសួរនាំហើយ វា រំលោភម៉ង រំលោភអស់ចិត្តអស់ចង់ សម្លាប់ចោលបំបាត់ភស្តុតាង។ ដល់ខ្ញុំចេះតែផ្ញើរនេះផ្ញើរនោះ ទៅ ដាក់បានអណ្តើកស្មោរអណ្តើកទៅ បើត្រី... ដឹកស្បៀងអាហារមានត្រីងៀតត្រីអី ចេះតែលួច គេទៅ លួចអារបស់យើងដឹងអាណាំ ប៉ុនអត់ហ៊ាន លួចច្រើនអេំ។ ត្រីងាតលួចមួយកន្ទុយ បើមួយ កន្ទុយសម័យនោះដូរមាសបានមួយជីអំបិលមួយកំប៉ុងពីរជី។ ដល់អញ្ចឹងទៅ គាត់បាក់ចិត្តស្រឡាញ់ខ្ញុំ ជើងល្អហាំ ... តាមពិតសម័យគាត់នៅរៀន តែកុងយន្តហោះ តែកុងពីឡុតដណ្តឹង ប៉ា គាត់អត់ឲ្យអេំ ដល់ខ្ញុំពីឡុតដែរ ពីឡុតឡើងដើមត្នោត ឥឡូវហ្នឹងដាំធ្វើស្ករ។ ដល់សម័យនេះ ខ្ញុំ ចេះនិយាយលេងជាមួយគាត់ ខ្ញុំថា

សម័យប៉ុលពត ខ្ញុំចិញ្ចឹមអ្នកឯង ដល់សម័យនេះអ្នកឯងចិញ្ចឹម ខ្ញុំវិញ គាត់ធ្វើការរហូតគាត់ធ្វើការខ្ញុំនៅតែផ្ទះ នៅផ្ទះហើយដើរផឹកស្រាប៉ុណ្ណឹងអាជីពខ្ញុំ។

កៈ ប្រហែលជាខ្ញុំសួរខ្លះៗទាក់ទងនឹង...

ខៈ សំណួរមួយឆ្លើយចង់១០នាទីអ៊ែ។

កៈ អត់ទេ! ល្អ អរគុណ និយាយច្រើន... និយាយកាន់តែច្រើនកាន់តែល្អ។ សួរពីដូចជាបងប្អូនអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរ?

ខៈ សម្រាប់ខ្ញុំអ៊ែ?

កៈ បាទ!

ខៈ ខ្ញុំបងប្អូន៧នាក់។

កៈ ៧នាក់ ហើយអ៊ុំទីប៉ុន្មាន?

ខៈ ខ្ញុំទី៧។

កៈ ទី៧ ពៅគេ?

ខៈ បាទ!

កៈ ហើយចាំឈ្មោះទាំងអស់របស់គេអ៊ែ?

ខៈ ចាំទាំងអស់។

កៈ ជួយរៀបរាប់ឈ្មោះ ហើយនិងអាយុរបស់ពួកគាត់។

ខៈ អូ! អាយុ...

កៈ បើអត់ចាំអាយុអត់អី ចាំតែឈ្មោះ...

ខៈ បងស្រីទី ១ ឈ្មោះគាត់ កូវ គយគី គាត់អាយុប្រហែលជា... គាត់ស្លាប់ជំនាន់វៀតណាមចូល វៀតណាមចូលគាត់អាយុប្រហែលជាខ្ទង់ចិតជាងអ៊ែ។ ហើយបងប្រុសទី ២ គាត់ស្លាប់

ដូចជាឆ្នាំ ១៩៦៩ អ៊េ... គាត់ស្លាប់នៅមន្ទីរពេទ្យរុស្សី គាត់ស្លាប់ដោយជម្ងឺអាំ។ ហើយបងស្រីបន្ទាប់មកបង ស្រីទី៣ បងស្រីទី៣ គាត់ស្លាប់នៅក្នុងព្រៃខ្មែរក្រហមជម្លៀទៅក្នុងព្រៃ ហើយសម័យហ្នឹងអត់មាន ថ្នាំពេទ្យអ៊េ ឈឺចាញ់តំបន់ចាញ់ឈឺស្លាប់ ហើយបើប្តីគាត់ ខ្មែរក្រហមសម្លាប់ចោល។ បើបងស្រីទី ៤ ម្តាយអែលឌើរអឹង ម្តាយអែលឌើរគាត់ស្លាប់ប្រហែលជាបីឆ្នាំអ៊ែ។ បាទ! ស្លាប់នៅខាងខេត្តកំពង់ ធំអាំ។ ហើយដល់បងប្រុសទី៥ គាត់ជាពីលុតយន្តហោះបងប្រុសខ្ញុំអាំ គាត់ធ្លាក់យន្តហោះស្លាប់ នៅពេលដែលកំពុងរៀនបើកបរ ស្លាប់នៅបាត់ដំបង ១៩៧២ ថ្ងៃ២៧ កក្កដា ឆ្នាំហ្នឹងខ្ញុំត្រូវប្រឡង ឌីផ្លូម បងខ្ញុំស្លាប់។ បើនៅសម័យប៉ុលពតក៏ប្រហែលជាមិនរស់ដែរ។ ប៉ុនបងខ្ញុំមិនតូចល្អិតដូចខ្ញុំអ៊េ គាត់មាឧធំអាំ មាឧធំហើយអ្នកលេងខ្លួន និងបងទី ៦ ធ្វើគ្រូបង្រៀននៅកំពង់ធំ ប៉ុនឥឡូវគាត់អាត្រែតអ៊ែ គាត់ចូលនិវត្តន៍អាំ ហើយនិងខ្ញុំប៉ុណ្ណឹង។

ក៖ ប្រហែលជាឪពុកម្តាយវិញ... ឪពុករបស់អ៊ុំប្រុសឈ្មោះអ្វីដែរ?

ខ៖ កូវ អឿ។ ម្តាយ ថ្លាន គឹមអាន។ ស្លាប់អស់ ម្តាយខ្ញុំស្លាប់នៅក្នុងព្រៃសម័យប៉ុលពត ដូចជាឆ្នាំ ១៩៧២–៧៣។

ក៖ ហើយដឹងថាគាត់មានអាយុប៉ុន្មានកាលគាត់ស្លាប់?

ខ៖ ម្តាយខ្ញុំអាយុប្រហែលជា... ចង់ចូលចិតអីអ៊ែ។ បាទ! ឪពុកខ្ញុំគាត់ស្លាប់ ១៩៨៦។ បាទ! ស្លាប់ ដោយជម្ងឺអាំ គេជម្លាសទៅស្រុកលើដែរ ប៉ុន្តែឪពុកខ្ញុំរស់ត្រូវបានត្រលប់មកភូមិវិញ។ ហើយម្តាយ ខ្ញុំស្លាប់ដោយសារគាត់មនុស្សចាស់ គាត់ឈឺច្រើនចឹងទៅ ហើយគាត់អត់មានថ្នាំសង្កូវស្លាប់នៅ ក្នុងព្រៃ ហើយក្នុង ព្រៃហ្នឹងមែនជិតផ្ទះទេណាំអែលឌើរ។ គេជម្លាសទៅ បើនិយាយទៅចង់៨០ គីឡូពីភូមិអាំ នៅតំបន់ ព្រៃ ព្រៃខ្លាម៉ងអាំ ជាប់ព្រំដែនព្រះវិហារអ៊ំ។ ហើយបររទេះថ្ងៃល្ងាចអី ជួន កាលខ្លាដើរកាត់មុខក៏មានដែរ កន្លែងហ្នឹង យប់ឡើងទាល់តែដុតភ្លើងជួនកាលខ្លាវាមកលួចចាប់ គោស៊ី បើសព្វថ្ងៃវិញរត់ទៅថៃអស់អ៊ែខ្លា ទៅមើលសួនសត្វនៅថៃនៅលើភ្នំអ៊ំសុទ្ធតែខ្លា សត្វអី ច្រើនអាំនៅថៃ។

ក៖ ហើយអ៊ុំចាំថាឪពុកម្តាយកើតដូចជាឆ្នាំណា?

ខ៖ ឆ្នាំណា... ឪពុកខ្ញុំដូចជា ១៩... ប៉ុន្មានអ៊េ ដូច ១៩... មើល ឆ្នាំ ១៩៨៦ គាត់អាយុ៨១ ដកតាមហ្នឹង ទៅ...

កៈ ១៩០៥...

ខៈ ប្រហែលប៉ុណ្ណឹង ហើយម្ដាយខ្ញុំប្រហែល១៩... ដូចជា... អត់ដឹងប៉ុន្មានអ៊េ។

កៈ អត់អីទេអ៊ុំ បើសិនអត់ចាំអត់អីទេអ៊ុំ។ ចុះតាយាយខាងឪពុក ចាំឈ្មោះគាត់?

ខៈ ចាំ! អាហ្នឹងយើងធ្វើពង្សប្រវត្តិអ៊ែហ្នឹង។

កៈ បាទ

ខៈ ជីតាខ្ញុំ ឈ្មោះគាត់ កូវ ប្រែង បាទ គាត់អាយុ ៨១ គាត់ស្លាប់ដែរ។ តែយាយខ្ញុំ ឈ្មោះគាត់ៗ អី ហ៊ុយទេ ឈ្មោះគាត់ ហ៊ុយ ហ្នឹងគាត់ស្លាប់មុនជីតាខ្ញុំ។ ខ្ញុំស្គាល់ជីតាខ្ញុំមួយ ហើយជីតាខ្ញុំគាត់ស្រឡាញ់ខ្ញុំអាំ ដោយសារខ្ញុំកូនពៅ តែខ្ញុំខូចជាងគេ ហើយគាត់សម្បូរលុយ ពេលទៅរៀនអីលួច លុយគាត់ អត់ដែលលួចច្រើនអ៊េ ពីររយ... ពីររៀលសម័យនោះច្រើនអាំ ហើយលុយគាត់ថ្មីច្រើង លុយអាក្រដាស់មួយរៀលៗដូរពីធនាគារនោះ លុយគាត់ទៅវត្តថ្វាយបង្គំលោក ដកពីរបីសន្លឹក... ស្អែកឡើងដកអាំ ឲ្យតែអត់លុយចាយលួចដក ហើយគាត់មានដឹងថាលុយបាត់អីបាបច្រើន។

កៈ បាបច្រើនហាស់ៗ។

ខៈ ជីតាខ្ញុំស្លាប់ដូចជា ១៩៧០ ហើយគាត់អ្នកមាន ជីតាខ្ញុំគាត់អ្នកមានអាំ នៅក្នុងស្រុកក្នុងភូមិហ្នឹង គេទទួលស្គាល់គាត់ គាត់ពូកែត្រូវ ដឹកស្រូវលក់ដល់វៀតណាម ហូជីមីញរាល់ថ្ងៃ ដឹកតាមទឹក។ ហើយរបស់គាត់ប្រើនៅផ្ទះសុទ្ធតែរបស់ទិញ... របស់បារាំង សម័យហ្នឹងបារាំងត្រួតត្រាអាំ តាំងពី ភួយតាំងពីទូដែកកេរ្ត៍គាត់នៅទាល់រាល់ថ្ងៃ គាត់បន្សល់ទុករាល់ថ្ងៃ។ ទូដែកលើក៨នាក់អីលើកអត់រួចអ៊េទូដែក ដាក់លើផ្ទះអីចង់ទ្រុឌផ្ទះ។

កៈ ចុះកេរ្តិ៍ខាងម្ដាយ?

ខៈ ខាងម្ដាយខ្ញុំគាត់នៅស្រុកបារាយណ៍ ខេត្តកំពង់ធំដែរ ប៉ុនឆ្ងាយពីគ្នា១០០គីឡូ។

កៈ តើគាត់ឈ្មោះអីដែរ?

ខៈ គាត់ឈ្មោះ ថ្លាន... ជីតាខ្ញុំ ឈ្មោះ ថ្លាន... ត្រកូលគាត់... ខ្ញុំអត់ដឹងត្រកូលទេ ខ្ញុំដឹងតែត្រកូលឪពុកមា ប្រហែលជាទាថ្លានមិនដឹង។ បាទ! ហើយយាយខាងម្ដាយខ្ញុំ ឈ្មោះ យាយតោ តែ

យាយ ស្លាប់អត់ ដឹងឆ្នាំណាអេ៎។ បើជីតាដូចគាត់ស្លាប់ក្នុងកំឡុងប្រហែលជាចិតលើសតិចតួច ដោយសារ សម័យខ្ញុំទៅ ជួបគាត់រាល់ឆ្នាំ ម្តាយខ្ញុំឲ្យខ្ញុំទៅយកលុយទៅជូនគាត់។ វប្បធម៌ខ្មែរ ពេលបុណ្យទាន គឺយកលុយទៅ ជូនឪពុកម្តាយអ៊ែ ដល់សម័យនេះកូនក្រៗ ពេលបុណ្យទាន ឪពុកម្តាយអត់ហាស់ ... កូនក៏អត់មានដែរ បានអីឲ្យយើងអែលខេរអឹងផ្ញើឲ្យ៥០ដុល្លា ម៉្សិលមិញ ម៉ែវាចូលគ្លីនិកអត់ គ្រប់ ផង។

ក៖ សួរពីឪពុកម្តាយម្តងទៀត សួរថាដូចជាឪពុកកើតនៅស្រុកណា?

ខ៖ ឪពុកខ្ញុំ?

ក៖ បាទ! ឪពុកអ៊ុំ។

ខ៖ កើតនៅស្រុកស្ទួង ខេត្តកំពង់ធំ។

ក៖ ហើយម្តាយវិញ?

ខ៖ ម្តាយកើតនៅ... បើតាមពិតទៅម្តាយខ្ញុំកើតនៅគៀនស្វាយ។ ខ្ញុំមានបងប្អូននៅគៀនស្វាយច្រើន ប៉ុនជីតា... ឪពុកខ្ញុំគាត់រកសី... ជីតាខ្ញុំ... ឪពុកម្តាយខ្ញុំអាណាំ ឪពុករបស់ម្តាយខ្ញុំគាត់រកស៊ី តាមទូកដល់គាត់រកស៊ីតាមទូក គេចេះតែថាឲ្យគាត់ថាតិចកូនធ្លាក់ទឹកងាប់ ហើយម្តាយខ្ញុំមានបង ប្អូនតែបីនាក់អេ៎។ អញ្ចឹងគាត់ទិញដីមួយនៅក្នុងស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ទិញដីទៅ គាត់ធ្វើ ផ្ទះនៅទៅ គាត់ឈប់រកស៊ីតាមទឹកអាំ ខ្លាចធ្លាក់កូន ប៉ុនតាមពិតគាត់កើតនៅ... តាមខ្ញុំដឹងអេំណាំ ខ្ញុំមិនដែលសួរគាត់អេ៎ កើតនៅគៀនស្វាយ ពីព្រោះតូចៗខ្ញុំធ្លាប់ទៅលេងបងប្អូននៅគៀនស្វាយ ខ្ញុំនៅតូច។

ក៖ ល្អមែនទែន អរគុណអ៊ុំ ឥឡូវសួរថាក្នុងជីវិតរបស់អ៊ុំប្រុស តើមានពេលណាដែលសប្បាយជាង គេ?

ខ៖ ហាំស ... សប្បាយជាងគេ... សម័យដែលសប្បាយជាងគេកំឡុងឆ្នាំ... មើល ដែលខ្ញុំដឹងក្តីអ៊ែ ហុកជា ទល់ឆ្នាំចិតសិប។ សម័យហ្នឹងអត់ទាន់មានសង្គ្រាមអេំណាំ បាទ ដល់ឆ្នាំ ៧០ រដ្ឋាភិបាល មានការធ្វើរដ្ឋប្រហាររដ្ឋប្រហារទម្លាក់ស្តេចសីហនុ សេនាប្រមុខលន់នល់ទម្លាប់សីហនុ ក៏ប៉ុន្តែជា ផែនការណ៍របស់សីហនុទាំងអស់ អត់មានផែនការណ៍ គ្មានអ្នកណាហ៊ានអេ៎ បើសីហនុបញ្ជាឲ្យ ធ្វើបានហ៊ានធ្វើ អានេះតាមខ្ញុំយល់ដឹងខ្លះៗអេណាំ។ តាំងពីសម័យហ្នឹងមក ខ្ញុំរៀននៅភ្នំពេញឆ្នាំ ១៩៧០ នៅតាម ស្រុកអត់មានសាលារៀនអេ៎ ត្រូវរៀតណាមចូលមក មាន

សង្គ្រាម អញ្ចឹងអ្នក ដែលមានលទ្ធភាពរត់ទៅរៀននៅភ្នំពេញ អ្នកអត់លទ្ធភាពគេឲ្យធ្វើខ្មែរក្រហម អញ្ចឹងខ្ញុំរត់ទៅរៀន នៅភ្នំពេញ បើខ្ញុំនៅក៏ងាប់ដែរ។

ក៖ អ៊ុំរៀនត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ខ្ញុំរៀនដល់ថ្នាក់ទីបញ្ចប់ឆ្នាំហ្នឹងត្រូវប្រឡងបាក់ឌុប តែអត់បានប្រឡងដោយសារគ្រាប់ផ្លោង ចូលច្រើនពេកឆ្នាំ១៩៧៥ហ្នឹងរំដោះ។ ប្រពន្ធខ្ញុំគាត់ជាប់បាក់ឌុបមុនខ្ញុំមួយឆ្នាំ ដោយសារខ្ញុំរៀន ធ្លាក់អាំ គាត់រៀនអត់ដែលធ្លាក់អេ៎។ គាត់ជាប់បាក់ឌុប គាត់ទៅបន្តនៅមហាវិទ្យាល័យនៅភ្នំពេញ តែរៀនអត់បានមួយឆ្នាំផងជម្លាសមកវិញ ហើយដើរពីភ្នំពេញមកដល់ហួសកំពង់ធំទៀត ធ្វើដំណើរដោយដើរហើយហោងសយអត់មានស្បែកជើងពាក់ទៀត វេទនាអាំដើរមែនដើរខ្លួនទទេរអេ៎ មានខោអាវជាប់ហ្នឹងខ្លួន ហើយស្បៀងអាហារតិចតួចដល់អស់ស្បៀងអាហារបានអី? អញ្ចឹងឪពុកមាម្ដាយមីងគាត់ គាត់មានដូចថាមាសពេជ្រអីជាប់ខ្លួនអាំ ដូរដោះសីដើម្បីរស់ដល់គាត់នេះទៅ រៀនមានអី? អត់មានអីទេ ជួនកាលម្ដាយមីងឲ្យគាត់ហូបចុកទៅជួនកាលគេឃ្លាន ប៉ុន្តែគេអត់ដែរ អត់មានអត់ទៅ។

ក៖ ប្រហែលជាសំណួរចុងក្រោយខ្ញុំចង់សួរថា បើសិនជាអ៊ុំមានអ្វីមួយដែលអាចប្រាប់ទៅដល់ដូច ជាកូនចៅនៅថ្ងៃអនាគត ដូចជាពាក្យប្រដៅឬក៏ជាការទូន្មានអ្វីខ្លះអ៊ុំចង់និយាយប្រាប់ពួកគាត់?

ខ៖ អឺ យើងមានតែទូន្មានគាត់ឲ្យខំរៀនតែប៉ុណ្ណឹង ហ្នឹង ខំរៀន ដើម្បីមានការងារធ្វើណាមួយ កូន ស្រីគាត់រៀនជិតដល់បាក់ឌុបដែរ គាត់អត់បានប្រឡងដែរ ហើយគាត់មានប្ដីលែងគ្នាបានតឹមហាក់ ហើយនិងកូនស្រីមួយពីរនាក់លែងគ្នា។ លែងគ្នាអត់មានមូលហេតុអីទេ អញ្ចឹងទៅកូនមួយហ្នឹង ពិបាកជាងគេ អញ្ចឹងយើងអាណិតកូនអាំ ចឹងចេះតែតឿនចៅឲ្យខំរៀនទៅ ខំរៀនក្រែងលោមាន ការងារធ្វើទៅ ជួយម្ដាយឲ្យធូរអាំ។

ក៖ បាទ!

ខ៖ សព្វថ្ងៃជីវភាពពួកយើងល្អតែមើលអេណាំ បើគេមើល មក គេថាខ្ញុំនៅតែគ្រាន់ ហើយខ្ញុំអត់មានប្រាក់ចំណូលទេ ចំណែកខ្ញុំរស់បានមុនចិញ្ចឹមក្រួច តែចេះ តែមានលុយចាយអេ៎។ ឥឡូវក្រូចចិញ្ចឹមអត់ចំណេញអេ៎ ចិញ្ចឹមមាន់ចូលឆ្នាំចិននេះលក់បានចូល ចង់១០០ដុល្លាដែរដាក់ក្រប៉ៅ។ ប៉ុន្តែការអែលឌើរតគ្នា គេហៅអញ្ជើញសំបុត្រការ សំបុត្រការពេញ ថ្ងៃ៣០នេះផារីអេ៎? ហើយផារីគេ រកខ្ញុំធ្វើឪពុកម្ដាយខាងកូនប្រុសទៀតជិន ផារី។ ហើយយប់ម្សិល មិញ ការមួយ

នៅនេះ ខាងលិចផ្ទះ អ៊ែលឌើរឡុង ហើយថ្ងៃ៦ការមួយនៅនេះ។ ថ្ងៃ៩ការមួយ... ការ នៅណា អ៊ែ។ ថ្ងៃ១០ការមីងភាព។ នៅ៤សំបុត្រទៀត ហើយនៅខែ៣អត់ដឹងមានប៉ុន្មានទៀតអ៊ែ អញ្ចឹង ការមួយតិចបំផុតចងដៃគេ៥ម៉ឺន អញ្ចឹងលក់មាន់បាន២០–៣០ម៉ឺនហ្នឹង៦ពោងត្រូវអស់អ៊ែ អា មាត់ខ្លួនឯងស៊ីសៀងដដែលហាស... ហើយម៉ាក់វាអត់ប្រាក់ខែទៀត គាត់អត់ប្រាក់ខែអ៊ែ បើ គាត់ នៅអត់បញ្ហាអ៊ែ ប៉ុន្តែគាត់អត់ជិត១ឆ្នាំអ៊ែ។

ក៖ បាទ! អញ្ចឹងប្រហែលជាសម្រាប់ថ្ងៃនេះ យើងមានសំណួរតែប៉ុណ្ណឹង បើអ៊ុំមានអ្វីចង់និយាយ ថែមអាចនិយាយបានតែបើអត់ អត់អី។

ខ៖ ប៉ុណ្ណឹងបានហើយណេ៎ វាច្រើនពេកអ៊ែ។

ក៖ បាទ! អញ្ចឹងដើម្បីបញ្ចប់ ខ្ញុំគ្រាន់តែបញ្ជាក់ថា យើងអាចយកការថតសម្លេងនេះបង្ហោះទៅវេប សាយរបស់ប៊ីវ៉ាយយូបានទេអ៊ុំ?

ខ៖ បាន មានអី។

ក៖ អរូខេ អរគុណច្រើន។

ខ៖ ឲ្យគេដឹងថាខ្ញុំនេះចោលសម័យប៉ុលពត។

ក៖ បាទ!